ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

# ស្ថានទូតកម្ពុជានៅម៉ាឡេស៊ី អន្តរាគមជួយពលរដ្ឋខ្មែរចំនួន៨នាក់

------------

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានអន្តរាគមដោះស្រាយបញ្ហា និងរៀបចំមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរចំនួន**៨នាក់** ដូចខាងក្រោម៖

(១) ពលការិនី **ស.ធ.ត** អាយុ២៥ឆ្នាំ មកពីស្រុកជីក្រែង ខេត្តសៀមរាប
(២) ពលការិនី **ឈ.ត** អាយុ២៣ឆ្នាំ មកពីស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ
(៣) ពលការិនី **ឈ.ម** អាយុ១៩ឆ្នាំ មកពីស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ
(៤) ពលការិនី **ប.ស.រ** អាយុ២៥ឆ្នាំ មកពីស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ

ពលការិនីទាំង៤នាក់ បានទៅម៉ាឡេស៊ីដោយខុសច្បាប់ និងធ្វើការជាអ្នកបោសសំអាត កាលពីខែវិច្ឆិកា ឆ្នាំ២០១៦ តាមរយៈក្រុមហ៊ុនមួយនៅកម្ពុជា។

**(៥)** ពលការិនី **ស.ស.ទ** អាយុ២៩ឆ្នាំ មកពីស្រុកចំការលើ ខេត្តកំពង់ចាម បានទៅម៉ាឡេស៊ីខុសច្បាប់ដោយខ្លួនឯង និងធ្វើការជាអ្នកបោសសំអាត កាលពីខែកុម្ភៈ ឆ្នាំ២០១៧ ។

ដោយធ្វើការលំបាក ពលការិនីទាំង៥នាក់ខាងលើ បានទៅស្ថានទូត នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៧ ស្នើសុំជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។ ស្ថានទូតបានសម្របសម្រួលជាមួយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ីសម្រាប់ពលការិនីទាំង**៥នាក់** ហើយពួកគេនឹងមកដល់អាកាសយានដ្ឋានអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**១៦** ខែ**ឧសភា** ឆ្នាំ**២០១៧** វេលាម៉ោង **១៧:៣៥**នាទី តាមជើងយន្តហោះ MH762 ។

**(៦)** ពលករ **ម.ល.ណ** អាយុ២៩ឆ្នាំ និង**(៧)** ភរិយាឈ្មោះ **ម.ម.រ** អាយុ២៤ឆ្នាំ ដែលអ្នកទាំងពីរមកពីស្រុកច្បារមន ខេត្តកំពង់ស្ពឺ បានទៅម៉ាឡេស៊ីខុសច្បាប់ដោយខ្លួនឯង ធ្វើការជាអ្នកជៀរជ័រកៅស៊ូនៅរដ្ឋ Kedah កាលពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១២។ ដោយចង់ត្រឡប់មកកម្ពុជា ប្ដី-ប្រពន្ធទាំងពីរនាក់បាននាំកូនស្រី (៨) ឈ្មោះ **ម.ស.រ** អាយុ២ឆ្នាំ ទៅស្ថានទូត នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧។

ស្ថានទូតបានសម្របសម្រួលជាមួយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី ហើយអ្នកទាំង**៣** បានមកដល់អាកាសយានដ្ឋានអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**១៣** ខែ**ឧសភា** ឆ្នាំ**២០១៧** វេលាម៉ោង**០៧:៣៥**នាទីព្រឹក តាមជើងយន្តហោះ AK536 ។

ក្នុងអំឡុងពេលរង់ចាំត្រឡប់មកកម្ពុជាវិញ ស្ថានទូតបានផ្ដល់កន្លែងស្នាក់នៅ និងម្ហូបអាហារបរិភោគសម្រាប់ពលរដ្ឋខ្មែរទាំង៨នាក់ខាងលើ ផងដែរ៕

ភ្នំពេញ, ថ្ងៃទី១៦ ខែ ឧសភា ឆ្នាំ ២០១៧

**ជុំ សុន្ទរី**

**អ្នកនាំពាក្យ**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ